ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៤៨៤៩.....សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣

ប្រកាសរួម
ស្តីពី
ការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ :

អនុញ្ញាតឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

ប្រការ ២ :

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

ប្រការ ៣ :

ក្រសួងសាធារណការ និងដឹកជញ្ជូន មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងដំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសាកល្បងប័ត្រចំណូល។

ប្រការ ៤ :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាល នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។ ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

ប្រការ ៥ :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្រប តាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៦ :

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

ប្រការ ៧ :

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ប្រការ ៨ :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

ប្រការ ៩ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១០ :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ ៩៨៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
ការចុះបញ្ជីយានយន្ត					
1	ទោចក្រយានយន្ត ក្រុមហ៊ុនKTS (ប័ណ្ណ+ស្លាក)	78,000	7ថ្ងៃ	អចិន្ត្រៃយ៍	
2	ត្រីចក្រយានយន្ត ក្រុមហ៊ុនKTS (ប័ណ្ណ+ស្លាក)	78,000	7ថ្ងៃ	អចិន្ត្រៃយ៍	
3	ស្លាកលេខរឺម៉ក(កន្ទុយ) ក្រុមហ៊ុនKTS (ស្លាក)	58,000	7ថ្ងៃ	អចិន្ត្រៃយ៍	
4	ប្តូរប័ណ្ណសម្គាល់(ពណ៌ លេខម៉ាស៊ីន) ក្រុមហ៊ុនKTS (ប័ណ្ណ)	55,000	7ថ្ងៃ	អចិន្ត្រៃយ៍	
5	ផ្ទេរកម្មសិទ្ធិស្លាកលេខ ក្រុមហ៊ុនKTS (ប័ណ្ណ)	55,000	7ថ្ងៃ	អចិន្ត្រៃយ៍	
6	ទុតិយតាស្លាកលេខ ក្រុមហ៊ុនKTS (ស្លាកលេខ)	55,000	7ថ្ងៃ		

ឯ១ ទរ្ទ ឯ ឯ្ងរ ទំ

ល.រ	ការពិពណ៌នា	តម្លៃផ្តាំ (លុយ)	ចំនួនដង់ស្យុងដែលអាចផ្តល់ជូន (ដង់ស្យុងទាប)	ប្រភេទសង	ចំណាំ
7	ហ៊ីបក្បាលម៉ូទ័រ (ហ៊ីប STAR)	60,000	៧ថ្ងៃ	អង្គរវត្ត	
8	ឧបករណ៍ចម្លងរូប (ហ៊ីប STAR)	60,000	៧ថ្ងៃ		
9	ហ៊ីបក្បាលម៉ូទ័រ (ហ៊ីប STAR)	65,000	៧ថ្ងៃ		
10	ចង្កៀងដាក់ផ្ទះបាយ (ហ៊ីប+ស្លឹក)	200,000	៧ថ្ងៃ	អង្គរវត្ត	
11	ចង្កៀងដាក់ផ្ទះបាយ (ហ៊ីប+ស្លឹក)	250,000	៧ថ្ងៃ		
12	ចង្កៀងដាក់ផ្ទះបាយ (ហ៊ីប+ស្លឹក)	160,000	៧ថ្ងៃ	អង្គរវត្ត	
13	ចង្កៀងដាក់ផ្ទះបាយ (ហ៊ីប+ស្លឹក)	200,000	៧ថ្ងៃ	អង្គរវត្ត	
14	ចង្កៀងដាក់ជញ្ជាំង (ហ៊ីប+ស្លឹក)	140,000	៧ថ្ងៃ	អង្គរវត្ត	
15	ចង្កៀងដាក់ជញ្ជាំង (ហ៊ីប+ស្លឹក)	160,000	៧ថ្ងៃ	អង្គរវត្ត	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
16	ទុតិយតាប័ណ្ណសម្គាល់រថយន្ត ក្រុមហ៊ុនKTS (បណ្ណ)	100,000	7ថ្ងៃ		
17	ស្លាកលេខខ្នាតធំ ក្រុមហ៊ុនKTS (ស្លាក)	300,000	7ថ្ងៃ	អចិន្ត្រៃយ៍	
ការប្រឡងយកបណ្ណបើកបរយានយន្ត និងប្តូរ ពន្យារ ទុតិយតា តតិយតា					
1	ប្រឡងទោចក្រយានយន្តប្រភេទ (ក1-ក2) ក្រុមហ៊ុនKTS (បណ្ណ+ទីលាន)	75,000	7ថ្ងៃ	5ឆ្នាំ	
2	ប្រឡងឡើងវិញ ទោចក្រយានយន្តប្រភេទ(ក1-ក2) ក្រុមហ៊ុនKTS (បណ្ណ+ទីលាន)	65,000	7ថ្ងៃ	5ឆ្នាំ	
3	ប្រឡងរថយន្តប្រភេទ (ខ) ក្រុមហ៊ុនKTS (បណ្ណ+ទីលាន)	180,000	7ថ្ងៃ	5ឆ្នាំ	
4	ប្រឡងរថយន្តប្រភេទ (គ.យ) ក្រុមហ៊ុនKTS (បណ្ណ+ទីលាន)	190,000	7ថ្ងៃ	3ឆ្នាំ	
5	ប្រឡងរថយន្តប្រភេទ (ង) ក្រុមហ៊ុនKTS (បណ្ណ+ទីលាន)	210,000	7ថ្ងៃ	3ឆ្នាំ	
6	ប្រឡងឡើងវិញ រថយន្តប្រភេទ(ខ-គ-យ-ង) ក្រុមហ៊ុនKTS (បណ្ណ+ទីលាន)	140,000	7ថ្ងៃ	5ឆ្នាំ	
7	ប្តូរ-ពន្យាបណ្ណបើកបរទោចក្រយានយន្ត(ក១-ក២) ក្រុមហ៊ុនKTS (បណ្ណ)	40,000	7ថ្ងៃ	5ឆ្នាំ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
8	ប្តូរ-ពន្យារបណ្ណបើកបររថយន្ត ក្រុមហ៊ុនKTS (បណ្ណ)	60,000	7ថ្ងៃ	5ឆ្នាំ	
9	ទុតិយតាបណ្ណបើកបរទោចក្រយានយន្ត ក្រុមហ៊ុនKTS (បណ្ណ)	45,000	7ថ្ងៃ		
10	ទុតិយតាបណ្ណបើកបររថយន្ត ក្រុមហ៊ុនKTS (បណ្ណ)	70,000	7ថ្ងៃ		
11	តតិយតាបណ្ណបើកបរទោចក្រយានយន្ត ក្រុមហ៊ុនKTS (បណ្ណ)	50,000	7ថ្ងៃ		
12	តតិយតាបណ្ណបើកបររថយន្ត ក្រុមហ៊ុនKTS (បណ្ណ)	80,000	7ថ្ងៃ		
ការចុះបញ្ជីធ្វើអាជីវកម្មសាលា និងសាខាសាលាបង្រៀនបើកបរយានយន្ត					
1	ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត	3,000,000	10ថ្ងៃ	3ឆ្នាំ	
2	បន្តសុពលភាពលិខិតអនុញ្ញាតធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត	1,200,000	7ថ្ងៃ	3ឆ្នាំ	
3	ផ្តល់ ឬបន្តសុពលភាពលិខិតអនុញ្ញាតធ្វើអាជីវកម្មសាខាសាលាបង្រៀនបើកបរយានយន្ត	800,000	7ថ្ងៃ	3ឆ្នាំ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានយន្ត					
- ការផ្តល់លិខិតអនុញ្ញាតយានយន្តធ្វើអាជីវកម្មក្នុង និងឆ្លងរាជធានី ខេត្ត					
1	រថយន្តដឹកទំនិញតូច(តិចជាង5តោន)	35,000	2-5ថ្ងៃ	1ឆ្នាំ	
2	រថយន្តដឹកទំនិញតូច(5តោន-10តោន)	40,000	2-5ថ្ងៃ	1ឆ្នាំ	
3	រថយន្តដឹកទំនិញធំ(លើសពី10តោន)	45,000	2-5ថ្ងៃ	1ឆ្នាំ	
4	រថយន្តដឹកអ្នកដំណើរតូច(តិចជាង15កៅអី)	35,000	2-5ថ្ងៃ	1ឆ្នាំ	
5	រថយន្តដឹកអ្នកដំណើរធំ(15កៅអីឡើង)	40,000	2-5ថ្ងៃ	1ឆ្នាំ	
6	រថយន្តដឹកសិស្ស-បុគ្គលិក-ទេសចរណ៍(តិចជាង15កៅអី)	35,000	2-5ថ្ងៃ	1ឆ្នាំ	
7	រថយន្តដឹកសិស្ស-បុគ្គលិក-ទេសចរណ៍(15កៅអីឡើង)	35,000	2-5ថ្ងៃ	1ឆ្នាំ	
8	ទោចក្រយានយន្តកង់បី	15,000	2-5ថ្ងៃ	1ឆ្នាំ	
9	ទោចក្រយានយន្តសណ្តោង	15,000	2-5ថ្ងៃ	1ឆ្នាំ	
- ការផ្តល់លិខិតអនុញ្ញាតរថយន្តធ្វើអាជីវកម្មដឹកទំនិញ និងអ្នកដំណើរឆ្លងដែន					
1	រថយន្តដឹកទំនិញ និងអ្នកដំណើរ	300,000	5ថ្ងៃ	1ឆ្នាំ	
2	រថយន្តមិនបំពេញណិជ្ជកម្ម	20,000	5ថ្ងៃ	1ឆ្នាំ	
- ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្រុមហ៊ុនដឹកជញ្ជូន					
1	ក្រុមហ៊ុនដឹកទំនិញ (ក្នុងប្រទេស)	1,500,000	10ថ្ងៃ	2ឆ្នាំ	
2	ក្រុមហ៊ុនដឹកជញ្ជូនឆ្លងដែន (ក្រៅប្រទេស)	1,000,000	10ថ្ងៃ	2ឆ្នាំ	
3	បន្តសុពលភាពក្រុមហ៊ុនដឹកជញ្ជូនក្នុងប្រទេស ឬបន្ថែមស្នាក់ការសាខាក្រុមហ៊ុន	1,000,000	10ថ្ងៃ	2ឆ្នាំ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
4	បន្តសុពលភាពក្រុមហ៊ុនដឹកជញ្ជូនឆ្លងដែន	800,000	10ថ្ងៃ	2ឆ្នាំ	
ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត					
1	រថយន្តទេសចរណ៍ ត្រឹម 4កៅអី ក្រុមហ៊ុន (CMVIC)	70,000	15នាទី	2ឆ្នាំ	ពិន័យលើការយឺតយ៉ាវ 500 រៀល/ថ្ងៃ (ចាប់គិតក្រោយពីរយៈពេល ៣០ថ្ងៃ បន្ទាប់ពីហួសកំណត់)
2	រថយន្តទេសចរណ៍ 5កៅអីឡើង ក្រុមហ៊ុន (CMVIC)	80,000	15នាទី	2ឆ្នាំ	
3	រថយន្តដឹកទំនិញ ក្រោម 1តោន ក្រុមហ៊ុន (CMVIC)	60,000	15នាទី	2ឆ្នាំ	ពិន័យលើការយឺតយ៉ាវ 2000 រៀល/1ថ្ងៃ (ចាប់គិតក្រោយពីរយៈពេល ៣០ថ្ងៃ បន្ទាប់ពីហួសកំណត់)
4	រថយន្តដឹកទំនិញ ក្រោម 2តោន (2A) ក្រុមហ៊ុន (CMVIC)	90,000	15នាទី	1ឆ្នាំ	
5	រថយន្តដឹកទំនិញចាប់ពី 2ដល់ 5តោន (3A) ក្រុមហ៊ុន (CMVIC)	95,000	15នាទី	1ឆ្នាំ	
6	រថយន្តដឹកទំនិញលើសពី 5តោន ដល់ 10តោន (3A) ក្រុមហ៊ុន (CMVIC)	100,000	15នាទី	1ឆ្នាំ	
7	រថយន្តដឹកទំនិញលើសពី 10តោន (3A) ក្រុមហ៊ុន (CMVIC)	110,000	15នាទី	1ឆ្នាំ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
8	រថយន្តដឹកអ្នកដំណើរពី 9នាក់ ដល់ 14នាក់ (2A) ក្រុមហ៊ុន (CMVIC)	90,000	15នាទី	1ឆ្នាំ	ពិន័យលើការយឺតយ៉ាវ 3000 រៀល/1ថ្ងៃ (ចាប់គិតក្រោយពីរយៈពេល ៣០ ថ្ងៃបន្ទាប់ពីហួសកំណត់)
9	រថយន្តដឹកអ្នកដំណើរត្រឹម 15នាក់ (2A) ក្រុមហ៊ុន (CMVIC)	95,000	15នាទី	1ឆ្នាំ	
10	រថយន្តដឹកអ្នកដំណើរលើសពី 15ដល់ 19នាក់ (3A) ក្រុមហ៊ុន (CMVIC)	100,000	15នាទី	1ឆ្នាំ	
11	រថយន្តដឹកអ្នកដំណើរចាប់ពី 20នាក់ឡើង (3A) ក្រុមហ៊ុន (CMVIC)	110,000	15នាទី	1ឆ្នាំ	
12	រថយន្តដឹកទំនិញ និងអ្នកដំណើរថ្មីធុនតូច (2A) ក្រុមហ៊ុន (CMVIC)	50,000	15នាទី	2ឆ្នាំ	ពិន័យលើការយឺតយ៉ាវ -រថ/ដឹកទំនិញ2000 រៀល/1ថ្ងៃ -រថ/ដឹកអ្នកដំណើរ 3000 រៀល/1ថ្ងៃ (ចាប់គិតក្រោយពីរយៈពេល ៣០ ថ្ងៃបន្ទាប់ពីហួសកំណត់)
13	រថយន្តដឹកទំនិញ និងអ្នកដំណើរថ្មីធុនធំ (3A) ក្រុមហ៊ុន (CMVIC)	55,000	15នាទី	2ឆ្នាំ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
14	រថយន្តទេសចរណ៍ ថ្មីគ្រប់ប្រភេទ ក្រុមហ៊ុន (CMVIC)	40,000	15នាទី	4ឆ្នាំ	ពិន័យលើការយឺតយ៉ាវ 500 រៀល/1ថ្ងៃ (ចាប់គិតក្រោយពីរយៈពេល ៣០ ថ្ងៃបន្ទាប់ពីហួសកំណត់)
15	គ្រឿចក្រយានយន្ត/ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ក្រុមហ៊ុន (CMVIC)	35,000	15នាទី	2ឆ្នាំ	
-ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានជុសជុលកែច្នៃ ដំឡើងយានយន្ត					
1	ការចុះបញ្ជី និងផ្តល់លិខិតធ្វើអាជីវកម្មយានដ្ឋានទំហំធំជាង ឬស្មើ250 ម៉ែត្រក្រឡា	400,000	10ថ្ងៃ	2ឆ្នាំ	
2	បន្តសុពលភាពលិខិតធ្វើអាជីវកម្មយានដ្ឋានទំហំធំជាង ឬស្មើ 250 ម៉ែត្រក្រឡា	200,000	7ថ្ងៃ	2ឆ្នាំ	
3	ចុះបញ្ជី និងផ្តល់លិខិតធ្វើអាជីវកម្មយានដ្ឋានទំហំតូចជាង ឬស្មើ 250 ម៉ែត្រក្រឡា	300,000	10	2ឆ្នាំ	
4	បន្តសុពលភាពលិខិតធ្វើអាជីវកម្មយានដ្ឋានទំហំតូចជាង ឬស្មើ 250 ម៉ែត្រក្រឡា	150,000	7ថ្ងៃ	2ឆ្នាំ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
សេវាកម្មសាធារណៈនាយកដ្ឋានឆ្នាំងសមុទ្រ និងមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត					
1	ការផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញសម្រាប់នាវិកលើនាវាសមុទ្រអន្តរជាតិ				
	១. នាវិកថ្នាក់គ្រប់គ្រង និងប្រតិបត្តិការ(មេបញ្ជាការនាវា នាយបើកបរ នាយបើកបរទី២/ទី៣ នាយយន្តការី នាយយន្តការីទី២/ទី៣ នាយទទួលបន្ទុកបើកបរ នាយទទួលបន្ទុកម៉ាស៊ីន នាយអគ្គីសនី វិទ្យុការី	200,000	7ថ្ងៃ	5ឆ្នាំ	ប្រកាសថ្មីស្តីពីនីតិវិធីផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញសម្រាប់នាវិក
	២. នាវិកថ្នាក់ជំនួយការ(នាយនាវិក នាវិកជំនាញបើកបរ នាវិកជំនាញម៉ាស៊ីន)	120,000	7ថ្ងៃ	5ឆ្នាំ	
	៣. បន្តសុពលភាពវិញ្ញាបនបត្រសមត្ថភាពជំនាញ (ថ្នាក់គ្រប់គ្រង ថ្នាក់ប្រតិបត្តិការ ថ្នាក់ជំនួយការ)	80,000	5ថ្ងៃ	5ឆ្នាំ	
2	ការផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញ និងវិញ្ញាបនបត្របដ្ឋិលេខសម្រាប់នាវិកលើនាវាឆ្លងកាត់ព្រំដែន				
	១.វិញ្ញាបនបត្រសមត្ថភាពជំនាញ(មេបញ្ជាការនាវា នាយបើកបរ នាយបើកបរទី២ នាយយន្តការី នាយយន្តការីទី២ នាយយន្តការីទី៣)	130,000	7ថ្ងៃ	5ឆ្នាំ	
	២.វិញ្ញាបនបត្របដ្ឋិលេខ(ប័ណ្ណបើកបរបដ្ឋិលេខ ប័ណ្ណយន្តការីបដ្ឋិលេខ)	50,000	5ថ្ងៃ	5ឆ្នាំ	
	៣.បន្តសុពលភាពវិញ្ញាបនបត្រសមត្ថភាពជំនាញ	60,000	5ថ្ងៃ	5ឆ្នាំ	

ឆ្នាំ ទី ១០ ខ្ពស់ខ្ពស់

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ម៉ោងធ្វើការ)	ចាយតាមសេវា	ទីតាំង
3	**ការផ្តល់ប័ណ្ណបរទេសសម្រាប់ទាក់ទងការងារជូនជនជាតិខ្មែរនៅក្រៅប្រទេស**				
១.ក	១.ប័ណ្ណបរទេសប្រភេទ ១	110,000	៧ថ្ងៃ	១ដង	ការិយាល័យ ១
ខ	២.ប័ណ្ណបរទេសប្រភេទ ២	100,000	៥ថ្ងៃ	១ដង	ការិយាល័យ ២
គ	៣.ប័ណ្ណបរទេសប្រភេទ ៣	50,000	៥ថ្ងៃ	១ដង	ការិយាល័យ ៣
ឃ	៤.ប័ណ្ណបរទេសប្រភេទ ៤ (ប័ណ្ណបរទេសសម្រាប់ការងារនៅបរទេស)	40,000	៥ថ្ងៃ	១ដង	ការិយាល័យ ៤
4	**ការផ្តល់សេវាវិញ្ញាបនប័ត្រ:អត្តសញ្ញាណប័ណ្ណ**				
ក	១.ផ្តល់សេវាថ្មី	300,000	៧ថ្ងៃ	១ដង	ការិយាល័យ ៣
ខ	២.ប្តូរអត្តសញ្ញាណប័ណ្ណ	100,000	៧ថ្ងៃ	១ដង	ការិយាល័យ ២
គ	៣.ជួសជុលអត្តសញ្ញាណប័ណ្ណ	150,000	១០ថ្ងៃ	១ដង	ការិយាល័យ ៣
5	**ការផ្តល់ប័ណ្ណបើកបរ**				
ក	១.ប័ណ្ណបើកបរ	130,000	៥ថ្ងៃ	១ដង	ការិយាល័យ ២
ខ	២.ប័ណ្ណបើកបរអន្តរជាតិ	90,000	៥ថ្ងៃ	១ដង	ការិយាល័យ ១
6	**ការផ្តល់សេវាព្រឹត្តប័ត្រ**				
ក	១.ប័ណ្ណបើកបរ				

ច្បាប់ចម្លងត្រឹមត្រូវ
ស្ថាប័នបម្រើសេវាសាធារណៈ
ក្រសួងមហាផ្ទៃ

ទាក់ទងសាខា/ទីតាំងផ្តល់សេវា:
ទាក់ទងផ្នែកព័ត៌មាន/ប្រឹក្សាយោបល់អំពីសេវា
ទូរស័ព្ទ: ០២៣-២៤១-២៤០
ទីតាំង: ផ្លូវជាតិលេខ ៦ ភូមិ ឃុំ ស្រុក ខេត្ត
ទាក់ទងផ្នែកព័ត៌មាន/ប្រឹក្សាយោបល់អំពីសេវា
ទូរស័ព្ទ: ០២៣-២៤១-២៤០
ទីតាំង: ផ្លូវជាតិលេខ ៦ ភូមិ ឃុំ ស្រុក ខេត្ត

ឆ ទ្រ ១៦ ច្បាប់ចុំ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	បណ្ណាគារ	ផ្នែក ៣
ក.ទាក់ទងនឹងដីធ្លី					
	ទាញដីតាមដំណើរ/ជាលក្ខណៈអចិន្ត្រៃយ៍ ចាប់ពី50-100ការ៉េ	150,000	7ថ្ងៃ	1ច្បាប់	ប្លង់ដីក្នុងទីប្រជុំជន ចាប់ផ្តើមពីថ្ងៃទី ០១/០៣/២០១៣
	ទាញដីតាមដំណើរ/ជាលក្ខណៈអចិន្ត្រៃយ៍ 250-400ការ៉េ:				
	អាចទាញដីតាមដំណើរ/ជាលក្ខណៈអចិន្ត្រៃយ៍ ចាប់ពី300ការ៉េ	200,000	7ថ្ងៃ	1ច្បាប់	
	ទាញដីតាមដំណើរ/ជាលក្ខណៈអចិន្ត្រៃយ៍ 400ការ៉េ:				
ខ.ស្នើសុំអត្តសញ្ញាណប័ណ្ណ					
	ស្នើសុំអត្តសញ្ញាណប័ណ្ណ	20,000	7ថ្ងៃ	1ច្បាប់	
គ.ស្នើសុំប្លង់		200,000	7ថ្ងៃ	1ច្បាប់	
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឃ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ង.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ច.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឆ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ជ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឈ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ញ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ដ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឋ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឌ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ណ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ត.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ថ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ទ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ធ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ន.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ប.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ផ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ព.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ភ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ម.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
យ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
រ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ល.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឝ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឞ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ហ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
អ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឡ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឣ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឤ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឥ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឦ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឧ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឩ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឪ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឫ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឬ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឭ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឮ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ញ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឋ.ស្នើសុំប្លង់					
	ស្នើសុំប្លង់	200,000	7ថ្ងៃ	1ច្បាប់	
ឍ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
	២.នាវា/សាឡាងដឹកទំនិញចំណុះ50-149តោន នាវាដឹកអ្នកដំណើរ/ដរចម្លង12-49កៅអី នាវានេសាទ/សណ្តោងកម្លាំង90-249សេះ	150,000	5ថ្ងៃ	1ឆ្នាំ	
	៣.នាវា/សាឡាងដឹកទំនិញចំណុះ150-300តោន នាវាដឹកអ្នកដំណើរ/ដរចម្លង50-100កៅអី នាវានេសាទ/សណ្តោងកម្លាំង250-400សេះ	200,000	7ថ្ងៃ	1ឆ្នាំ	
	៤.នាវា/សាឡាងដឹកទំនិញចំណុះលើស300តោន នាវាដឹកអ្នកដំណើរ/ដរចម្លងលើស100កៅអី នាវានេសាទ/សណ្តោងកម្លាំងលើស400សេះ	250,000	7ថ្ងៃ	1ឆ្នាំ	
8	**ការប្តូរប័ណ្ណ ឬវិញ្ញាបនបត្ររបស់នាវិក ឬរបស់នាវា**				
	១.វិញ្ញាបនបត្រសមត្ថភាពជំនាញ(ខូច ឬបាត់)	40,000	5ថ្ងៃ	ដូចមុន	
	២.ប័ណ្ណសម្គាល់នាវា (ខូច ឬបាត់)	80,000	5ថ្ងៃ	អចិន្ត្រៃយ៍	
	៣.ប័ណ្ណសម្គាល់នាវា(កែច្នៃលក្ខណៈសម្គាល់នាវា)	150,000	10ថ្ងៃ	អចិន្ត្រៃយ៍	
9	**ច្បាប់អនុញ្ញាតស្ថាបនានាវា**				
	១. នាវាមានចំណុះផ្ទុកតិចជាង 20តោន	200,000	10ថ្ងៃ		
	២. នាវាមានចំណុះផ្ទុក 20-149តោន	260,000	15ថ្ងៃ		
	៣. នាវាមានចំណុះផ្ទុក 150-300តោន	400,000	20ថ្ងៃ		
	៤. នាវាមានចំណុះផ្ទុកលើសពី 300តោន	500,000	20ថ្ងៃ		

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
10	ការបង្កើតយានដ្ឋានសាងសង់ ឬជួសជុលនាវា				
	១.លិខិតអនុញ្ញាតបង្កើត និងសាងសង់	2,000,000	30ថ្ងៃ		
	២.លិខិតអនុញ្ញាតប្រតិបត្តិការ	1,600,000	15ថ្ងៃ	2ឆ្នាំ	
11	ការសាងសង់កំពង់ផែក្នុងស្រុក				
	១.លិខិតអនុញ្ញាតបង្កើតកំពង់ផែ	2,000,000	30ថ្ងៃ		
	២.លិខិតអនុញ្ញាតសាងសង់កំពង់ផែ	2,000,000	30ថ្ងៃ		
	៣.លិខិតអនុញ្ញាតប្រតិបត្តិការ	3,000,000	15ថ្ងៃ	2ឆ្នាំ	
12	លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមសមុទ្រ				
	១. កម្រៃជើងសារសេវាកម្ម	200,000	10ថ្ងៃ	1ឆ្នាំ	
	២.ក្រុមហ៊ុនដឹកជញ្ជូនតាមសមុទ្រ	200,000	10ថ្ងៃ	1ឆ្នាំ	
	៣.បូមស្តារ	1,000,000	10ថ្ងៃ	1ឆ្នាំ	
ដឹកជញ្ជូនផ្លូវទឹក					
1	ការផ្តល់បណ្ណសម្គាល់ជលយាន				
	1-ផ្តល់បណ្ណសម្គាល់ជលយានថ្មី(បញ្ជាក់អ៊ូរ/ប្លង់/ពន្ធនាំចូលជលយាន ជាបន្ទុករបស់ម្ចាស់ជលយាន)	250,000	10ថ្ងៃ	អចិន្ត្រៃយ៍	
	2-ប្តូរម៉ាស៊ីន ឬពណ៌ ឬកែមាឌ ឬប្តូរម្ចាស់កម្មសិទ្ធិជលយាន (បញ្ជាក់អ៊ូរ/ប្លង់កែមាឌ/ប្រថាប់ត្រា ជាបន្ទុករបស់ម្ចាស់ជលយាន)	100,000	10ថ្ងៃ	អចិន្ត្រៃយ៍	
	3-ប្តូរបណ្ណ(ប្តូរឈ្មោះជលយាន)ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន	100,000	10ថ្ងៃ	អចិន្ត្រៃយ៍	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
2	ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន				
	1-ជលយានក្នុងស្រុក	150,000	០៧ថ្ងៃ	៦ខែសំបកឈើ ឬ ១២ខែសំបកដែក	
	2-ជលយានឆ្លងដែន	400,000	០៧ថ្ងៃ	៦ខែសំបកឈើ ឬ ១២ខែសំបកដែក	
	3-ជលយានដឹកម្លង	100,000	០៧ថ្ងៃ	៦ខែសំបកឈើ ឬ ១២ខែសំបកដែក	
3	លិខិតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក				
	1-ជលយានក្នុងស្រុក	200,000	០៧ថ្ងៃ	១២ខែ	
	2-ជលយានដឹកជញ្ជូនឆ្លងដែន	400,000	០៧ថ្ងៃ	១២ខែ	
	3-ជលយានដឹកម្លង	100,000	០៧ថ្ងៃ	១២ខែ	
4	ផ្តល់បណ្ណបើកបរ/បណ្ណយន្តការី				
	1-ប្រឡងបណ្ណបើកបរជលយាន(ពិនិត្យសុខភាព សំបុត្រពេទ្យ ជាបន្ទុករបស់សាមីជន)	100,000	០៧ថ្ងៃ	៣ ឆ្នាំ	
	2 -ប្រឡងបណ្ណយន្តការី(ពិនិត្យសុខភាព សំបុត្រពេទ្យ ជាបន្ទុករបស់សាមីជន)	80,000	០៧ថ្ងៃ	៣ ឆ្នាំ	
	3 -ប្តូរបណ្ណបើកបរជលយាន/ប្តូរបណ្ណយន្តការី(ពិនិត្យសុខភាព សំបុត្រពេទ្យ ជាបន្ទុករបស់សាមីជន)	80,000	០៧ថ្ងៃ	៣ ឆ្នាំ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	ផ្សេងៗ
4-ថ្លៃអាជ្ញាប័ណ្ណបើកបរ/ការប្តូរប័ណ្ណបើកបរ					
ប័ណ្ណសម្គាល់ខ្លួន/ប្រវត្តិរូប (ទាន់ពេលវេលា)		80,000	១ថ្ងៃ	២ ឆ្នាំ	
ប្តូរប័ណ្ណអាជ្ញាប័ណ្ណបើកបរ ពាក់ព័ន្ធនឹងការ ប្តូរប័ណ្ណ ការបន្ថែមប្រភេទ ការលុបប្រភេទ ការបន្ថែមពិន្ទុ ការលុបពិន្ទុ ការបាត់ប័ណ្ណ ការដាក់ប័ណ្ណចូលវិញ					
1-ប្តូរប័ណ្ណអាជ្ញាប័ណ្ណបើកបរ (ទាន់ពេលវេលា)		500,000	៣ថ្ងៃ	៣ ឆ្នាំ	
2-ការបន្ថែមប្រភេទ / ការលុបប្រភេទ		200,000	៣ថ្ងៃ	៣ ឆ្នាំ	
3 -ប្តូរប័ណ្ណអាជ្ញាប័ណ្ណបើកបរ		150,000	៣០ថ្ងៃ	១ ឆ្នាំ	

ត្រូវនឹងដើម

ភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣

- ចំពោះជនបរទេសធ្វេីអត្តឃាតត្រូវបង្ក្រាបតាមច្បាប់ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៨៨០.....សហវ..

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣

ប្រកាសរួម
ស្តីពី
ការផ្តល់រង្វាន់លើកទឹកចិត្តជូន
ក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- យោងប្រកាសរួមលេខ ៩៨៩ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

ប្រការ ១ :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញការកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

ប្រការ ២ :

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

ប្រការ ៣ :

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងសាធារណការ និងដឹកជញ្ជូន និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ៩៨៩ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងសាធារណការ និងដឹកជញ្ជូន និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៤ :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៧០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ២៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលដែលប្រមូលបាន ។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៧០% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ចំនួន ២៩% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃចំណូលដែលប្រមូលបាន ។

ប្រការ ៥ :

រដ្ឋបាលកណ្តាលនៃក្រសួងសាធារណការ និងដឹកជញ្ជូន និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀត របស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងសាធារណការ និងដឹកជញ្ជូនដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ (ប្រាក់ចំណូលដែលបានកាត់ទុកជាមុន) ។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូល: ត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
- ចំពោះមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយ: ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

ប្រការ ៦ :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ប្រការ ៧ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨ :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ភាគ ឈន់

រដ្ឋមន្ត្រី
ក្រសួងសាធារណការ និងដឹកជញ្ជូន

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសៀនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
«ដើម្បីជូនជ្រាប»
- ដូចប្រការ ៨ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ